00628395

លេខ/No: D427/2/10

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / 11 / 2010
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**នៅចំពោះអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ:**

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧-អវតក-កសចស (**អ.ប.ជ ១៤៥**)

ដាក់ជូនទៅ : អង្គបុរេជំនុំជម្រះ

កាលបរិច្ឆេទដាក់ឯកសារ : ២៩ វិច្ឆិកា ២០១០

ភាគីអ្នកដាក់ឯកសារ : មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី

ភាសាដើម : ភាសាខ្មែរ

**ចំណាត់ថ្នាក់ឯកសារ:**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: សាធារណៈ / Public

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សេចក្តីអង្កេតរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹង**
**បណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ជំទាស់នឹងដីកាដំណោះស្រាយ**

---

| | |
|---|---|
| **ដាក់ជូនដោយ:** | **ដាក់ជូនទៅ:** |
| **សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី** | **អង្គបុរេជំនុំជម្រះ** |
| លោកស្រី ជេត វណ្ណលី | ចៅក្រម ប្រាក់ គឹមសាន |
| លោកស្រី ទី ស្រ៊ីនណា | ប្រធាន ចៅក្រម Rowan DOWNING |
| លោក វ៉ែន ពៅ | ចៅក្រម ន័យ ថុល |
| **ជំនួយការ៖** | ចៅក្រម Catherine MARCHI-UHEL |
| ហេង សុនតុន | ចៅក្រម ហួត វុទ្ធី |

ហួត គង់ឃូ
សួស ស៊ីនួន

ចំលងជូន

| សហព្រះរាជអាជ្ញា | សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី | |
|---|---|---|
| លោកស្រី ជា លាង | ស៊ិនសុវ៉ន | យុង ផានិត |
| លោក Andrew CAYLEY | ឡៅ ជុនធី | ហុង គីមសួន |
| លោក យ៉េត ចរិយា | គង់ ពិសី | ម៉ុច សុវណ្ណារី |
| លោក William SMITH | គីម ម៉េងឃី | |
| លោក សេង ប៊ុនឃាង | Martine JACQUIN | |
| **មេធាវីការពារក្តី:** | Annie DELAHAIE | Patrick BAUDOIN |
| មេធាវីការពារក្តី អៀង សារី | Marie GUIRAUD | Laure DESFORGES |
| លោក អាង ឧត្តម | Françoise GAUTRY | Barnabe NEKUIE |
| លោក Michael G.KANAVAS | Daniel LOSQ | Isabelle DURAND |
| មេធាវីការពារក្តី អៀង ធីរិទ្ធ | Nicole DUMAS | Julien RIVET |
| លោក ផាត់ ពៅស៊ាង | Pascal AUBOIN | Phillipe CANONE |
| លោកស្រី Diana ELLIS QC | Lyma Thuy NGUYEN | Mohandev MOHAN |
| មេធាវីការពារក្តី នួន ជា | Olivier BAHOUGNE | Silke STUDZINSKY |
| លោក សុន អារុន | Emmanuel JACOMY | Emmanuel ALTIT |
| លោក Michiel PESTMAN | Christine MARTINEAU | |
| មេធាវីការពារក្តី ខៀវ សំផន | Elizabeth Rabesandratana | |
| លោក ស សុវាន | Ferdinand DJAMMEN-NZEPA | |
| លោក Jacques VERGES | Fabienne TRUSSES-NAPROUS | |

## I. សេចក្តីផ្តើម

១. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមដាក់សេចក្តីអង្កេតរបស់ខ្លួនទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍ចំនួនបី ("បណ្តឹងឧទ្ធរណ៍")[1] ដែលបានដាក់ដោយឡែកពីគ្នាដោយ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ("ដើមបណ្តឹងឧទ្ធរណ៍") ជំទាស់ទៅនឹងដីកាដំណោះស្រាយទាំងមូល និងផ្នែកខ្លះនៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតដែលបានចេញនៅថ្ងៃទី ១៥ កញ្ញា ២០១០[2]។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា បណ្តឹងឧទ្ធរណ៍ទាំងបីខាងលើនេះគួរត្រូវបានបដិសេធចោល ដោយសារមូលហេតុថា វាត្រូវបានធ្វើឡើងដោយមិនស្របតាមកាលៈទេសៈ និងមិនអាចទទួលយកបាន។

២. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដោយក្តីគោរពទៅអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ដើម្បីដាក់សេចក្តីសង្កេតនេះតែមួយភាសាដែលជាភាសាដើម ចំណែកឯអត្ថបទបកប្រែនឹងត្រូវបានដាក់ជូនទៅ អ.ប.ជ នៅពេលក្រោយ បន្ទាប់ពីអង្គភាពបកប្រែរបស់ អង្គជំនុំជម្រះវិសាមញ្ញ ("អ.វ.ត.ក") បានបញ្ចប់ការបកប្រែវាហើយ។

## II. អំពីប្រវត្តិនៃនីតិវិធី

៣. កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ដោយកំណត់បទចោទទៅលើជនជាប់ចោទ នួន ជា អៀង សារី និងអៀង ធីរិទ្ធ ក្នុងអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ សីហា ១៩៤៩ និងការរំលោភទៅលើក្រមព្រហ្មទណ្ឌខ្មែរឆ្នាំ១៩៥៦[3]។

---

[1] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/2/1 ។ បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/3/1 ។ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/1/6 ។

[2] ដីកាដំណោះស្រាយចុះថ្ងៃទី ១៥ កញ្ញា ២០១០, ឯកសារលេខ D427។

[3] ដីកាដំណោះស្រាយចុះថ្ងៃទី ១៥ កញ្ញា ២០១០, ឯកសារលេខ D427, កថាខណ្ឌ ១៦១៣។

៤. ដើមបណ្តឹងឧទ្ធរណ៍ នួន ជា បានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់ទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០[4] ដើមបណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ បានដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០[5]។ ដើមបណ្តឹងឧទ្ធរណ៍ អៀង សារី បានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់ទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០[6]។

៥. សហព្រះរាជអាជ្ញាបានដាក់ការឆ្លើយតបរួមរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ទាំងបីខាងលើកាលពីថ្ងៃទី ១៩ វិច្ឆិកា ២០១០[7]។ ហើយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល៥ថ្ងៃក្នុងការដាក់សេចក្តីសង្កេតរបស់ខ្លួនទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ទាំងនោះ ដោយគាំទ្រចម្លើយតបរបស់សហព្រះរាជអាជ្ញា ដែលរយៈពេល ៥ ថ្ងៃនេះរាប់ចាប់តាំងពីថ្ងៃដែលចម្លើយតបរបស់សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងទៅដល់ភាគី[8]។

## III. ភាពអាចទទួលយកបាននៃសេចក្តីសង្កេត

៦. ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី៥ ខាងលើ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់សេចក្តីសង្កេតរបស់ខ្លួនក្នុងរយៈពេល៥ថ្ងៃ ចាប់តាំងពីថ្ងៃដែលចម្លើយតបរបស់សហព្រះរាជអាជ្ញាត្រូវ

---

[4] បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/3/1។

[5] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/2/1 ។

[6] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/1/6 ។

[7] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និងអៀង ធីរិទ្ធប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៩.១១.២០១០ ឯកសារ D427/1/17។

[8] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំដាក់ចម្លើយតបរួមទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី អៀង ធិរិទ្ធ និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើសុំបន្ថែមចំនួនទំព័រកំណត់ ចុះថ្ងៃទី២៨.១០.២០១០, ឯកសារ D427/1/8។

បានជូនដំណឹងទៅឱ្យភាគី ស្របទៅតាមសេចក្តីសម្រេចរបស់ អ.ប.ជ ចុះថ្ងៃទី២៨ តុលា ២០១០[9]។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងទៅឱ្យភាគីតាមរយៈសារអេឡិកត្រូនិចកាលពីថ្ងៃទី ២៤ វិច្ឆិកា ២០១០ ដូច្នេះ កាលបរិច្ឆេទកំណត់ចុងក្រោយនៃការដាក់សេចក្តីសង្កេតរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺចប់ថ្ងៃ ច័ន្ទ ទី២៩ វិច្ឆិកា ២០១០ ។ យោងតាមអំណះអំណាងខាងលើ កាលបរិច្ឆេតកំណត់សម្រាប់ដាក់សេចក្តីសង្កេតនេះត្រូវបានដាក់នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ ដែលនាំឱ្យសេចក្តីសង្កេតនេះអាចទទួលយកបាន។

## IV. សេចក្តីសង្ខេបនៃអំណះអំណាងក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

៧. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសង្កេតឃើញថា ដើមបណ្តឹងឧទ្ធរណ៍បានលើកអំណះអំណាងក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់នឹងដីកាដំណោះស្រាយដោយផ្អែកជាសំខាន់លើមូលដ្ឋានដូចតទៅ:

**ក. ទឡ្ហីករណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ នួន ជា៖**

១. សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំលើអង្គច្បាប់ដោយដើមបណ្តឹងឧទ្ធរណ៍ នួន ជា បានលើកឡើងថា អ.វ.ត.ក មិនមានយុត្តាធិការលើបទល្មើសអន្តរជាតិទេ ដោយសារថា អ.វ.ត.ក គឺជាសាលាក្តីព្រហ្មទណ្ឌជាតិ[10](បណ្តឹងឧទ្ធរណ៍ នួន ជា)។

២. ច្បាប់ព្រហ្មទណ្ឌជាតិឆ្នាំ១៩៥៦ មិនបានចែងពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋកម្មសង្គ្រាម ថាជាបទល្មើសព្រហ្មទណ្ឌទេ[11] (បណ្តឹងឧទ្ធរណ៍ នួន ជា)។

៣. ច្បាប់ អ.វ.ត.ក មិនបានចែងអំពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំង

---

[9] ដូចដើងទំព័រខាងលើ, កថាខណ្ឌទី ៤។

[10] បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/3/1, កថាខណ្ឌ ២៤- ២៦។

[11] បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/3/1, កថាខណ្ឌ ២៧- ២៩។

មនុស្សជាតិ បទឧក្រិដ្ឋកម្មសង្គ្រាម ថាជាបទល្មើសព្រហ្មទណ្ឌទេ[12](បណ្តឹងឧទ្ធរណ៍ នួន ជា)។

៤. គោលការណ៍នីត្យានុកូលភាពអន្តរជាតិ មិនបានចែងអំពីបទល្មើសព្រហ្មទណ្ឌជាតិទេ[13] (បណ្តឹងឧទ្ធរណ៍ នួន ជា)។

៥. ការកំណត់បទល្មើសព្រហ្មទណ្ឌដោយអានុភាពប្រតិសកម្មរំលោភលើគោលការណ៍នីត្យានុកូលភាពជាតិ[14](បណ្តឹងឧទ្ធរណ៍ នួន ជា)។

៦. អ.វ.ត.ក ជាតុលាការជាតិ ដូច្នេះ គ្មានយុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវដែលចោទលើជនត្រូវចោទទេពីព្រោះ ឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវទាំងនោះ មិនមែនជាច្បាប់ជាតិដែលយកមកអនុវត្តនៅអំឡុងពេលរបបកម្ពុជាប្រជាធិប្បតេយ្យឡើយ[15](បណ្តឹងឧទ្ធរណ៍ នួន ជា)។

**ខ. ទឡ្ហីករណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ អៀង សារី**

១. អ.វ.ត.ក ពុំមានយុត្តាធិការលើ អៀង សារី ឡើយពីព្រោះ៖

. អៀង សារីត្រូវបានជំនុំជម្រះ និងកាត់ទោសរួចហើយ ចំពោះអំពើឧក្រិដ្ឋកម្មដែល អ.វ.ត.ក ចោទប្រកាន់លើគាត់ [16](បណ្តឹងឧទ្ធរណ៍ អៀង សារី)។

. គាត់ត្រូវបានលើកលែងទោស និងអនុគ្រោះទោស ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែល

---

[12] បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/3/1, កថាខណ្ឌ ៣០- ៣២។

[13] បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/3/1, កថាខណ្ឌ ៣៣- ៣៤។

[14] បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/3/1, កថាខណ្ឌ ៣៥- ៣៧។

[15] បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/3/1, កថាខណ្ឌ ២៤- ៣៧។

[16] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/1/6, កថាខណ្ឌ ៤២-១០២។

អ.វ.ត.ក ចោទលើរូបគាត់[17] (បណ្តឹងឧទ្ធរណ៍ អៀង សារី)។

. ថិរវេលានៃឧក្រិដ្ឋកម្មដែលចោទប្រកាន់បានផុតរលត់ និងការពន្យាពេលចោទប្រកាន់ គឺជាគោលការណ៍ប្រតិសកម្មដែល អ.វ.ត.ក បំពានលើគោលការណ៍នីត្យានុកូល និងសមភាពរបស់ដើមបណ្តឹងឧទ្ធរណ៍ចំពោះមុខច្បាប់[18](បណ្តឹងឧទ្ធរណ៍ អៀង សារី)។

. អ.វ.ត.ក ជាតុលាការជាតិ ដូច្នេះ គ្មានយុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវដែលចោទលើជនត្រូវចោទទេ ពីព្រោះឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវទាំងនោះមិនមែនជាច្បាប់ជាតិដែលយកមកអនុវត្តនៅអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យឡើយ[19] (បណ្តឹងឧទ្ធរណ៍ អៀង សារី)។

២. សហចៅក្រមស៊ើបអង្កេតបានយកច្បាប់ស្តីពី ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តដោយមានការភ័ន្តច្រឡំ ពីព្រោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានកំណត់និយមន័យដោយភ័ន្តច្រឡំ។ លើសពីនេះទៅទៀត សហចៅក្រមស៊ើបអង្កេតបានយកច្បាប់ស្តីពី ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមកអនុវត្តដោយមានការភ័ន្តច្រឡំ ពីព្រោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវចោទ ផ្នែកខ្លះមិនមែនជាផ្នែកនៃទំនៀមទំលាប់អន្តរជាតិឡើយ ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩[20](បណ្តឹងឧទ្ធរណ៍ អៀង សារី)។

៣. ទម្រង់នៃការទទួលខុសត្រូវចេញពី សហឧក្រិដ្ឋកម្មរួម ត្រូវបានកំណត់និយមន័យដោយមានការភ័ន្តច្រឡំ ហើយសហចៅក្រមស៊ើបអង្កេតយកទម្រង់នៃការទទួលខុសត្រូវនេះមកអនុវត្តដោយ

---

[17] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/1/6, កថាខណ្ឌ ២១- ១០២ ។

[18] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/1/6, កថាខណ្ឌ ១៣៨- ១៧៩ ។

[19] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/1/6, កថាខណ្ឌ ១០៣-១៣៥ ។

[20] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/1/6, កថាខណ្ឌ ១៨០-២៣១ ។

ភ័ន្តច្រឡំ[21] (បណ្ដឹងឧទ្ធរណ៍ អៀង សារី)។

៤. ទម្រង់នៃការទទួលខុសត្រូវនៃផែនការរួម ការញុះញង់ ការបញ្ជា និង ការជួយ និងជំរុញ ត្រូវបានកំណត់និយមន័យដោយមានការភ័ន្តច្រឡំ ដូច្នេះ សហចៅក្រមស៊ើបអង្កេតបានយកមក អនុវត្តដោយមានការភ័ន្តច្រឡំដែរ[22](បណ្ដឹងឧទ្ធរណ៍ អៀង សារី)។

## គ. ទឡ្ហីករណ៍របស់ដើមបណ្ដឹងឧទ្ធរណ៍ អៀង ធីរិទ្ធ

១. អ.វ.ត.ក ជាតុលាការជាតិ និងពុំមានយុត្តាធិការលើឧក្រិដ្ឋកម្មជាតិដែលអាជ្ញាយុកាល របស់បទល្មើសផុតរលត់នោះទេ និងការពន្យាពេលនៃការចោទប្រកាន់គឺជាគោលការណ៍ប្រតិសកម្ម ដែល អ.វ.ត.ក បំពានលើគោលការណ៍នីត្យានុកូល និងសមភាពរបស់ដើមបណ្ដឹងឧទ្ធរណ៍ចំពោះមុខ ច្បាប់[23] (បណ្ដឹងឧទ្ធរណ៍ អៀង ធីរិទ្ធ)។

២. អ.វ.ត.ក គ្មានយុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវដែលបាន ចោទប្រកាន់ឡើយ ពីព្រោះ អ.វ.ត.ក ជាតុលាការជាតិ ហើយ ឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុស ត្រូវទាំងនេះ មិនមែនជាផ្នែកនៃច្បាប់ជាតិដែលត្រូវបានអនុវត្តក្នុងអំឡុងពេលឆ្នាំ ១៩៧៥-១៩៧៩ នោះ ទេ[24](បណ្ដឹងឧទ្ធរណ៍ អៀង ធីរិទ្ធ)។

៣. សហចៅក្រមស៊ើបអង្កេត យកឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានកំណត់និយម ន័យដោយភ័ន្តច្រឡំ មកអនុវត្តដោយភ័ន្តច្រឡំ ហើយឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនមែនជាផ្នែក

---

[21] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/1/6, កថាខណ្ឌ ២៤៩-២៧២ ។

[22] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/1/6, កថាខណ្ឌ ២៧៣-២៨២ ។

[23] បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/2/1, កថាខណ្ឌ៧៣-៧៨ ។

[24] បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/2/1, កថាខណ្ឌ១២-៧២ ។

នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩[25] (បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ)។

៤. ដីកាដំណោះស្រាយ ត្រូវបានចេញដោយរំលោភលើ សិទ្ធិរបស់ដើមបណ្តឹងឧទ្ធរណ៍ក្នុងការទទួលបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌[26] (បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ)។

## V. អំណះអំណាងរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបណ្តឹងឧទ្ធរណ៍

៨. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា រាល់ការលើកឡើងជាទឡ្ហីករណ៍នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ដូចមាននិយាយនៅក្នុងកថាខ័ណ្ឌ៧ ខាងលើនេះ គឺមិនអាចទទួលយកបាននោះទេ ហើយយើងខ្ញុំសូមប្រកាសការគាំទ្ររាល់ទឡ្ហីករណ៍ទាំងអស់របស់ សហព្រះរាជអាជ្ញានៅក្នុងចម្លើយតបរួមរបស់ខ្លួន[27]ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ជំទាស់នឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០១០។

## VI. សវនាការផ្ទាល់មាត់មិនមានភាពចាំបាច់នោះទេ

៩. ដើមបណ្តឹងឧទ្ធរណ៍ អៀង សារី និងអៀង ធីរិទ្ធ បានស្នើសុំ អ.ប.ជ ឲ្យរៀបចំសវនាការផ្ទាល់មាត់ដេញដោលជាសាធារណៈ ក្នុងការសម្រេចសេចក្តីទៅលើបណ្តឹងឧទ្ធរណ៍ទាំងនេះ[28] ដោយដើមបណ្តឹងឧទ្ធរណ៍មិនបានលើកឡើងអំពីមូលហេតុដែលថាសវនាការផ្ទាល់មាត់ជាសាធារណៈពិតជាមានភាពចាំបាច់នោះទេ ដោយគ្រាន់តែលើកថា មានភាពស្មុគស្មាញ សំខាន់ទាក់ទងនឹងភាពអាចជឿ

[25] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/2/1, កថាខណ្ឌ ៩៥-១០១ ។

[26] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/2/1, កថាខណ្ឌ ៦០-៦៣ ។

[27] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៩ វិច្ឆិកា ២០១០។ ឯកសារលេខ D427/1/17។

[28] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/1/6, កថាខណ្ឌ ៤, បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/2/1, កថាខណ្ឌ ១០២ ។

ទុកចិត្តបាននៃ អ.វ.ត.ក តែប៉ុណ្ណោះ។ វិធាន ៧៧ (៣)(ខ) ចែងថា បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អ.ប.ជ អាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។ នេះមានន័យថា សិទ្ធរបស់ដើមបណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានសវនាការផ្ទាល់មាត់ មិនមានភាពដាច់ខាតតម្រូវឱ្យ អ.ប.ជ ត្រូវតែរៀបចំសវនាការផ្ទាល់មាត់នោះទេ។ម្យ៉ាងវិញទៀត ដោយហេតុថា ការបើកសវនាការទៅលើបណ្តឹងឧទ្ធរណ៍ណាមួយត្រូវបានកំណត់ថា មិនមានភាពចាំបាច់នោះ អ.ប.ជ គួរត្រូវយកពេលវេលាដ៏មានសារៈសំខាន់នេះមកពិនិត្យមើលនូវអំណះអំណាង និងការឆ្លើយតបរបស់ភាគីទាំងសងខាងជាលាយលក្ខណ៍អក្សរមកធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តី ដែលអាចធានាបាននូវដំណើរការការងារទាន់ពេលវេលាតាមការកំណត់របស់ច្បាប់ និងជាសវាងការខ្ជះខ្ជាយធនធានរបស់ អ.វ.ត.ក ច្រើនពេក។

១០. ក្នុងករណីនេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើថា ការសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍ខាងលើនេះដោយ អ.ប.ជ គួរត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។

## VII. សេចក្តីសន្និដ្ឋាន និង សំណូមពរ

១១. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា បណ្តឹងឧទ្ធរណ៍ដែលមិនត្រឹមត្រូវដូច្នេះ ត្រូវតែត្រូវបានសម្រេចបដិសេធចោលដោយ អ.ប.ជ។

សេចក្តីដូចបានជំរាបជូនខាងលើ សូម អ.ប.ជ មេត្តាសម្រេច៖

១. ប្រកាសថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន។

២. បញ្ជូនដីកាដំណោះស្រាយទៅអង្គជំនុំជម្រះសាលាដំបូងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

00628405

**លេខ**/No: D427/2/10

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ)

សូមអង្គបុរេជំនុំជម្រះ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០

AVOCAT ATTORNEY AT LAW ... OF CAMBODIA

| | | |
|---|---|---|
| ....................................... | ....................................... | ....................................... |
| ជេត វណ្ណលី | ទី ស្រ៊ុនណា | វ៉ែន ពៅ |